# កម្ពុជាផ្ដល់សញ្ញាវិជ្ជមានចំពោះការបន្តការិយាល័យសិទ្ធិមនុស្ស

Friday 30 December 2011

ជាង សុខា-Vincent MacIsaac



លោក Christophe Peschoux ដែលបានចាកចេញពីកម្ពុជា។ **រូបថត ហេង ជិវ័ន**

ភ្នំពេញៈ រាជរដ្ឋាភិបាលកម្ពុជា បានបន្ទន់ជំហររបស់ខ្លួន ដោយអាចអនុញ្ញាតឲ្យការិយាល័យសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ប្រចាំកម្ពុជា នៅបន្តមានវត្តមាននៅកម្ពុជាតទៅទៀត បន្ទាប់ពីថ្ងៃផុតកំណត់ នៅថ្ងៃស្អែកនេះទៅ។ នេះបើតាមលោករដ្ឋមន្ត្រីការបរទេស ហោ ណាំហុង ដែលថ្លែងប្រាប់ក្រុមអ្នកយកព័ត៌មានកាលពីម្សិលមិញ។

ការបន្ទន់ជំហរបែបនេះ ត្រូវបានធ្វើឡើង បន្ទាប់ពីមានការថ្លែងរិះគន់ខ្លាំងក្លាមួយ កាលពីឆ្នាំមុន ពីលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលបានបញ្ជាឲ្យបិទការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស និងបណ្ដេញតំណាងប្រចាំប្រទេសនេះ គឺលោក Christophe Peschoux ដោយលើកឡើងថា តំណាងរូបនេះ បានដើរតួជាអ្នកនាំពាក្យឲ្យក្រុមប្រឆាំង។

នៅពេលសួរលោកថា តើអនុស្សរណៈនៃការយោគយល់គ្នា រវាងការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស និងរដ្ឋាភិបាលនឹងត្រូវបានបន្តឬអត់? លោក ហោ ណាំហុង បានប្រាប់ភ្នំពេញ ប៉ុស្ដិ៍ថា រដ្ឋាភិបាលកំពុងពិនិត្យ ហើយលោកបានថ្លែងថា៖«ខ្ញុំគិតថា វានឹងមិនមានបញ្ហាអ្វីនោះទេ»។

បុគ្គលិកនៅការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស អង្គការសហប្រជាជាតិ បានបដិសេធ មិនធ្វើអត្ថាធិប្បាយ ប៉ុន្តែទទួលស្គាល់ថា ពួកគេ បានទទួលការជូនដំណឹង អំពីការបញ្ចប់ និងគម្រោងការងារនៅឆ្នាំក្រោយ។

លោក អ៊ូ វីរៈ ប្រធានមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា បានថ្លែងថា វានឹងជារឿងគួរឲ្យភ្ញាក់ផ្អើល ប្រសិនបើការិយាល័យនេះត្រូវបិទ។ លោកថ្លែងបន្តថា៖ «ដោយសារមានសម្ពាធអន្តរជាតិ ការធ្វើជាប្រធានអាស៊ានរបស់កម្ពុជានៅឆ្នាំក្រោយ និងការខិតខំប្រឹងប្រែងរបស់កម្ពុជា ដើម្បី

ទទួលបានកៅអី សមាជិកមិនអចិន្ត្រៃយ៍នៅក្រុមប្រឹក្សាសន្តិសុខអង្គការសហ ប្រជាជាតិ វានឹងជាភាពល្ងង់ ប្រសិនបើកម្ពុជា មិនបន្ត អនុស្សរណៈនៃការយោគយល់គ្នានេះទេ»។

ស្ថានទូតអាមេរិក បានថ្លែងដដែល អំពីទស្សនៈរបស់ខ្លួន ដែលថា ការិយាល័យសិទ្ធិមនុស្ស របស់អង្គការសហប្រជាជាតិ ដើរតួយ៉ាងសំខាន់ នៅទីនេះ។ លោក Sean McIntosh មន្ត្រីកិច្ចការសាធារណៈ នៅស្ថានទូតបានថ្លែងថា៖ «ដូចលោកស្រី ហ៊ីឡារី គ្លីនតុន បានថ្លែង ក្នុងអំឡុង ដំណើរទស្សនកិច្ចរបស់លោកស្រីមកកម្ពុជា កាលពីឆ្នាំមុន ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស គឺជាធនធានដ៏មានតម្លៃ។ ការងាររបស់ ការិយាល័យនេះ គឺសំខាន់ ហើយយើងចង់ឃើញការិយាល័យនេះបន្តមានតទៅទៀត»។ លោកបានបន្តថា៖ «កិច្ចសហប្រតិបត្តិការ រវាង សហរដ្ឋអាមេរិក និងរដ្ឋាភិបាលកម្ពុជា បានជួយក្នុងការលើកកម្ពស់សិទ្ធិមនុស្ស លុបបំបាត់ការជួញដូរមនុស្ស និងលើកកម្ពស់នីតិរដ្ឋ»។

លោក អ៊ូ វីរៈ បានថ្លែងថា រដ្ឋាភិបាល បានប្រើអនុស្សរណៈនៃការយោគយល់គ្នាជាឧបករណ៍ ដើម្បីបណ្តេញលោក Peschoux ដែលជាអ្នក គាំទ្រជនរងគ្រោះនៃការរំលោភបំពានសិទ្ធិមនុស្ស មិនសំចៃមាត់ និងគាំទ្រសហគមន៍ ដែលបាត់បង់ដីធ្លី ដោយសារក្រុមហ៊ុនឯកជន និង បុគ្គលដែលពាក់ព័ន្ធនឹងរដ្ឋាភិបាល។

លោក Peschoux បានចាកចេញពីប្រទេសកម្ពុជា កាលពីខែឧសភាដើម្បីកាន់តំណែងមួយនៅទីក្រុងហ្សឺណែវ (Geneva) ដោយថ្លែងថា ការ ចាកចេញរបស់លោក គឺជាការស្ម័គ្រចិត្ត។

លោក អ៊ូ វីរៈ បានថ្លែងថា៖ «យើងទាំងអស់គ្នា ដឹងការពិត ចំពោះហេតុផលពិតប្រាកដដែលលោក Peschoux បានចាកចេញ»។

អង្គការឃ្លាំមើលសិទ្ធិមនុស្ស ក៏បានថ្លែងផងដែរថា៖«ខ្លួនគាំទ្រខ្លាំងក្លា ចំពោះការបន្ត នៃការិយាល័យនេះ នៅទីនេះ»។ លោក Phil Robertson អនុប្រធានគ្រប់គ្រងផ្នែកអាស៊ី របស់អង្គការនេះបានថ្លែងថា៖ «ការិយាល័យសិទ្ធិមនុស្សគឺសំខាន់ណាស់ដើម្បីការពារអ្នកការពារ សិទ្ធិមនុស្ស ក្នុងប្រទេសកម្ពុជា»។

លោកបន្តថា អង្គការឃ្លាំមើលសិទ្ធិមនុស្ស កំពុងផ្តោតការយកចិត្តទុកដាក់ខ្លាំងក្លា លើការធានាថា អាណត្តិនៃការការពារសិទ្ធិមនុស្ស ក្នុង អនុស្សរណៈនៃការយោគយល់គ្នានេះត្រូវបានបន្ត»។

លោក Robertson បន្តថា សមត្ថភាពរបស់ការិយាល័យអង្គការសហប្រជាជាតិ ក្នុងការស៊ើបអង្កេតដោយឯករាជ្យ ទៅលើករណីរំលោភបំពាន លើសិទ្ធិមនុស្ស គឺសំខាន់ណាស់។ លោកបានបន្ថែមថា វាអាចក្រើនរំឭកឲ្យមានការប្រុងប្រយ័ត្នដល់អ្នកដទៃទៀត អំពីស្ថានភាពសិទ្ធិមនុស្ស ក្នុងប្រទេសកម្ពុជា៕ PS

ប្រភពព័ត៌មាន The Phnom Penh Post